# តើយើងអាចជួយអ្នកណាបានខ្លះ ?

យើងផ្តោតជាចំបងនៅក្នុងតំបន់ ឡូស់អេនជីឡេស ជាមួយនឹងសេវាកម្មនិងជំនួយមួយចំនួន នៅក្នុងតំបន់ អ័រេញ ( Orange County ) ។

ខណៈពេលដែលសេវាកម្មរបស់យើងខ្ញុំបើកចំហរសម្រាប់លោកអ្នកគ្រប់គ្នា យើងផ្តល់អទិភាពដល់លោកអ្នកដែលមិនសូវចេះ ឬមិនចេះភាសាអង់គ្លេសសោះ ព្រមទាំងអ្នកធ្វើអន្តោប្រវេសន៏ និងគ្រួសារដែលមានប្រាក់ចំណូលតិច។

ភាគច្រើននៃសេវាកម្មនិងកម្មវិធីរបស់យើងខ្ញុំគឺ មិនគិតកំរៃលុះត្រាត្រូវបានកំណត់សម្គាល់។

យើងខ្ញុំមិនទទួលបញ្ហាព្រហ្មទណ្ឌ គ្រោះថ្នាក់បុគ្គល ឬបញ្ហាគ្រោះថ្នាក់ចរាចណ៏នោះទេ។

សូមទូរស័ព្ទមកយើងខ្ញុំសម្រាប់ជំនួយ ហើយយើងខ្ញុំមិនទទួលអ្នកមកដោយផ្ទាល់ដោយគ្មានការណាត់ទេ។



6/2015

## លេខទូរស័ព្ទជំនួយឥតគិតថ្លៃ
## ៨៨៨-៣៤៩-៩៦៩៥

**888-349-9695**
អង់គ្លេស

**800-520-2356**
ចិន

**800-867-3126**
ខ្មែរ

**800-867-3640**
កូរ៉េ

**800-914-9583**
ថៃ

**800-267-7395**
វៀតណាម


ASIAN AMERICANS
ADVANCING JUSTICE
LOS ANGELES

info@advancingjustice-la.org
www.advancingjustice-la.org


# តើយើងអាចជួយអ្នកដោយរបៀបណា ?



*Building Upon the Legacy of the*
*Asian Pacific American Legal Center*




## តើយើងជានរណា ?

មជ្ឈមណ្ឌលច្បាប់នៃជនជាតិអាស៊ីអាមេរិកកាំង ដើម្បីលើកកំពស់យុត្តិធម៌ ប្រចាំក្រុងឡូស់អេនជឺឡេស ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៣ គឺជាអង្គការធំជាងគេរបស់ថ្នាក់ជាតិផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋ សម្រាប់ជនជាតិអាស៊ី អាមេរិកកាំង ជនជាតិដើមហាវ៉ៃ និង ជនជាតិនៅកោះបាស៊ីហ្វិក។ ជារៀងរាល់ឆ្នាំ យើងជួយមនុស្សរាប់ពាន់នាក់ ដែលជាបុគ្គល និងក្រុម ខណៈពេលដែលយើងកំពុងកសាងផងដែរនូវសំម្លេងដែលខ្លាំងមួយ សម្រាប់សិទ្ធិពលរដ្ឋ តាមរយៈការណែនាំ និងសេវាកម្មផ្សេងៗផ្នែកច្បាប់ រឿងក្តី ការតស៊ូរមតិ ការបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ។

## តើយើងមានធ្វើអ្វីខ្លះ ?

មជ្ឈមណ្ឌលលើកកំពស់យុត្តិធម៌ ប្រចាំក្រុងឡូស់អេនជឺឡេស ផ្តល់ពត៌មានផ្នែកច្បាប់ដោយឥតគិតថ្លៃ តាមទូរស័ព្ទ ឬជួបដោយផ្ទាល់។ ចំពោះសុំណុំរឿងខ្លះយើងក៏អាចផ្តល់ជំនួយបន្ថែម ឬការតំណាងផ្នែកច្បាប់ផងដែរ ដោយមិនគិតកំរៃ ឬដោយតំលៃទាប។

លើសពីនេះទៀត យើងក៏អាចផ្តល់ការធ្វើបទបង្ហាញបែបអប់រំដោយឥតគិតថ្លៃលើបញ្ហាជាច្រើន និងថ្នាក់ឬការបណ្តុះបណ្តាលផ្សេងៗ លើបញ្ហាចំៗដូចជា ការងារស៊ីវិល និងភាសាអង់គ្លេសជាភាសាទីពីរ ឬការអភិវឌ្ឍន៏ភាពជាអ្នកដឹកនាំ។

## បញ្ហា

ចូលសញ្ជាតិ

ការក្លែងបន្លំដល់អ្នកប្រើប្រាស់

អំពើហឹង្សាក្នុងគ្រួសារ ( ច្បាប់គ្រួសារនិងរឿងអន្តោប្រវេសន៏ )

រកជំនួយថែទាំសុខភាព

ជំនួយលំនៅស្ថាន

អន្តោប្រវេសន៏ (រាប់ទាំងការសុំអនុគ្រោះច្បាប់សំរាប់កុមារ និងគ្រួសារដែលធ្វើអន្តោប្រវេសន៏ ដោយមិនគិតកំរៃ ឬដោយតំលៃទាប )

សុវត្ថិភាពជាតិស្តីពីការរើសអើងក្រោយព្រឹត្តការណ៍ ៩/១១

ការរើសអើងពូជសាសន៏ ឬភាសា ( ក្នុងកន្លែងការងារ ឬ វិស័យអប់រំ )

សិទ្ធិការងារ (រាប់ទាំងប្រាក់កំរៃ និងចំនួនម៉ោងធ្វើការ ថែមម៉ោងការងារ អាហារ និងម៉ោងសំរាក )



## ការទទួលបានការថែទាំសុខភាព

មុននឹងមជ្ឈមណ្ឌលលើកកំពស់យុត្តិធម៌ ប្រចាំក្រុងឡូស់អេនជឺឡេស អាចជួយលោកអ្នកបាន យើងប្រហែល ត្រូវតែធ្វើការស្រង់ពត៌មានមួយចំនួនដើម្បីកំណត់ថាតើលោកអ្នកទទួលសេវាកម្មរបស់យើងខ្ញុំដែរឬអត់។ បុគ្គលិកស្រង់ពត៌មាននឹងសួរអំពីបញ្ហាច្បាប់ ប្រាក់ចំណូលរបស់អ្នក ចំនួនសមាជិកគ្រួសារ និងពត៌មានផ្ទាល់ខ្លួនផ្សេងៗ។ យើងខ្ញុំនឹងមិនចែកចាយពត៌មាន របស់លោកអ្នកទៅនណារម្នាក់ឡើយក្រៅពីការិយាល័យរបស់យើងខ្ញុំ។

អាស្រ័យតាមបញ្ហាច្បាប់របស់អ្នក យើងខ្ញុំអាចផ្តល់អោយអ្នកនូវពត៌មានផ្នែកច្បាប់ ឬការណែនាំតាមរយៈទូរស័ព្ទ។ ក្នុងសំណុំរឿងខ្លះ យើងខ្ញុំអាចផ្តល់ជំនួយ ឬការតំណាងផ្នែកច្បាប់បាន។ ប្រសិនបើយើងមិនអាចដោះស្រាយ លើបញ្ហារបស់អ្នកបាន យើងនឹងព្យាយាមផ្តល់អោយអ្នកនូវពត៌មានអំពីក្រុមច្បាប់ដទៃទៀត ដើម្បីអោយទាក់ទង។

សូមចំណាំ: យើងជួយមនុស្សអោយបានច្រើនតាមតែអាចធ្វើទៅបាន ប៉ុន្តែគួរអោយសោកស្តាយ យើងខ្ញុំមិនអាចជួយបានគ្រប់គ្នាដែលទូរស័ព្ទមកយើងខ្ញុំនោះទេ ដោយសារតែលក្ខណ្ឌជំនួយថវិការ និងចំនួនបុគ្គលិក។

